ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ១៣៧/២៦ ក.ប/ខ.ល

# សារលិខិតជូនពរ

**សូមគោរពជូន**

**ឯកឧត្តម ឯក សំអុល**

**ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

***ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

ក្នុងឱកាសចម្រើនជន្មាយុដ៏ថ្លៃថ្លាដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៦ នេះ ខ្ញុំបាទ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមប្រសិទ្ធពរជ័យ ជូនចំពោះ **ឯកឧត្តម ឯក សំអុល ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ទទួលបាននូវបញ្ញាញាណភ្លឺថ្លាវាងវៃ កម្លាំងពលំមាំមួន ជន្មាយុយឺនយូរ ចាកផុតពីរោគាព្យាធិនានានិងសម្រេច ជោគជ័យដ៏ត្រចះត្រចង់ក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមរបស់ **ឯកឧត្តម** ដើម្បីបន្តចូលរួមជានាការពារឯករាជ្យជាតិ អធិបតេយ្យភាព និងបូរណភាពដែនដី អភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនជឿនលឿន លើកតម្កើងកិត្យានុភាព របបរាជានិយមឱ្យទទួលបានការគាំទ្រពីមជ្ឈដ្ឋានអន្តរជាតិ ក្រោមម្លប់ដ៏ត្រជាក់នៃ**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្ទសាធុការពរ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរ ជូនចំពោះ **ឯកឧត្តម** និង**លោកជំទាវ** ព្រមទាំងក្រុមគ្រួសារជាទីស្រឡាញ់ សូមសមប្រកប ដោយព្រះពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម ឯក សំអុល ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវគារវភក្តីភាពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ។

ថ្ងៃ ពុធ ៨កើត ខែ ទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ កក្កដា ឆ្នាំ២០២៦

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ**

**ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**ហេង សួរ**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩